# វិបត្តិហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ក្នុងតំបន់

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់លោក Jayant Menon* ក្នុងសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ និងព័ត៌មានផ្សេងទៀតស្រង់ពីអត្ថបទរបស់លោកនៅក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨_០៩ បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។*

## ផលប៉ះពាល់នៅលើកំណើនផលិតផល

ពិភពលោកបាននិងកំពុងប្រយុទ្ធប្រឆាំងនឹងវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្ងន់ធ្ងរ មិនធ្លាប់ជួបប្រទះពីមុនមក ។ វិបត្តិបានចាប់ផ្តើមក្នុងឆ្នាំ២០០៧ ជាមួយនឹងការរលំរលាយកម្ចីមានអ៊ីប៉ូតែកលេខ២ នៅសហរដ្ឋអាមេរិក ហើយវិវត្តរីតតែធ្ងន់ធ្ងរ និងរីករាលដាលកាន់តែធំឡើង ។ នៅក្រោយសង្គ្រាមលោកលើកទី២ នេះជាលើកទីមួយហើយដែលមហាអំណាចសេដ្ឋកិច្ចទាំង ៣ (G3) រួមមាន សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន បានធ្លាក់ចុះសេដ្ឋកិច្ចក្នុងពេលតែមួយ ។ កំណើនផលិតផលរបស់សហរដ្ឋអាមេរិក បានធ្លាក់ចុះពី ២% នៅឆ្នាំ២០០៧ មកត្រឹម ១,១% នៅឆ្នាំ២០០៨ ដែលធ្វើឱ្យអត្រាអត់ការងារធ្វើ កើនដល់ ៧,៨% នៅខែធ្នូ ២០០៨ ។ នៅពេលជាមួយគ្នានោះ កំណើនផលិតផលនៅអឺរ៉ុបថយចុះពី ២,៦% មកត្រឹម ០,៧% ។ តំបន់អឺរ៉ូ បានធ្លាក់ចូលក្នុងវិបត្តិនេះជាផ្លូវការនៅចុងឆ្នាំ២០០៨ បន្ទាប់ពីស្ថាប័នហិរញ្ញវត្ថុសំខាន់ៗបានទទួលរងគ្រោះដោយផ្ទាល់ពីវិបត្តិ ហើយវិនិយោគពាណិជ្ជកម្ម និងចំណាយលើការប្រើប្រាស់បានថយចុះ ។ ជាមួយគ្នានោះ សេដ្ឋកិច្ចជប៉ុនធ្លាក់ចុះប្រហែល ៣% ហើយកំណើនជំរុញដោយការនាំចេញ ក៏ត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតំរូវការសាកលលោកថយចុះ (តារាង ១) ។ មកដល់ពេលនេះ វិបត្តិបានជះឥទ្ធិពលស្ទើរតែទូទាំងសាកលលោក ហើយបញ្ហាវិបត្តិកើតចេញពីណា វាលែងសំខាន់ទៀតហើយ ។ ការពិចារណាដែលសំខាន់ជាងគេ គឺធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ច ងើបឡើងវិញពីការខូចខាតយ៉ាងធ្ងន់ធ្ងរ បង្កឡើងដោយវិបត្តិ និងជៀសវាងកុំឱ្យរឿងនេះកើតមានជាថ្មី ដោយផ្អែកលើការយល់ដឹង និងដំណោះស្រាយលើបញ្ហាដែលនាំឱ្យមានវិបត្តិ ។ កង្វះខាតបទបញ្ញត្តិ និងការត្រួតពិនិត្យពីគោលការណ៍ប្រុងប្រយ័ត្ន លើកម្ចីអ៊ីប៉ូតែកលេខ២ បាននាំឱ្យវិស័យហិរញ្ញវត្ថុដួលរលំ ដូច្នេះវាជាបញ្ហាចំបង ដែលត្រូវតែលើកមកដោះស្រាយភ្លាមៗ ។

តំបន់អាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង (សំដៅជារួមដល់ អាស៊ាន ប្រទេសឧស្សាហកម្មថ្មី ឬ NIEs និងប្រទេសចិន) ក៏មិនបានគេចផុតពីផលប៉ះពាល់នៃវិបត្តិដែរ ហើយវាខុសស្រឡះពីការវាយស្មានពីដំបូងថា ប្រទេសភាគច្រើនក្នុងតំបន់ នឹងគេចផុតពីការរីករវរសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះ ។ ទោះជាយ៉ាងនេះក្តី តំបន់នេះអាចទ្រាំទ្រនឹងវិបត្តិបានប្រសើរជាងតំបន់ផ្សេងទៀត ក្នុងពិភពលោក ។ នៅឆ្នាំ២០០៨ កំណើនផលិតផលធ្លាក់មកត្រឹម ៦,១% ធៀបនឹង ៩% នៅឆ្នាំ២០០៧ ។ កំណើន ផសស អាស៊ានបានថយចុះមកត្រឹម ៤,៣% ធៀបនឹង ៦,៣%កាលពីឆ្នាំមុន ។ កំណើន ផសស របស់ប្រទេសឧស្សាហកម្មថ្មី ថយចុះយ៉ាងខ្លាំង មកត្រឹម ១,៨% នៅឆ្នាំ២០០៨ ធៀបនឹង ៥,៦% នៅឆ្នាំ២០០៧ ។ នៅពេលជាមួយគ្នានោះ កំណើននៅប្រទេសចិនថយចុះគួរឱ្យកត់សំគាល់អស់ប្រហែល ៣% បន្ទាប់ពីបានឡើងខ្ពស់បំផុត កាលពីឆ្នាំមុន (តារាង ១) ។

## ផលប៉ះពាល់នៅលើផលិតកម្ម និងពាណិជ្ជកម្ម

ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បានស្តែងឡើងដោយការថយចុះផលិតកម្ម និងពាណិជ្ជកម្ម ។ ផលិតផលកម្មន្តសាលសាកល បានធ្លាក់ចុះ ដោយសារតំរូវ

**តារាង ១: កំណើន ផសស**

| | 2006 | 2007 | 2008 | បំរែបំរួល 07-08 |
|---|---|---|---|---|
| តំបន់អាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង | 8.7 | 9 | 6.1 | -2.9 |
| តំបន់អាស៊ាន | 6 | 6.5 | 4.3 | -2.2 |
| ប្រទេសឧស្សាហកម្មថ្មី | 5.5 | 5.6 | 1.8 | -3.8 |
| ចិន | 11.6 | 11.9 | 9 | -2.9 |
| ជប៉ុន | 2 | 2.4 | -0.7 | -3.1 |
| សហរដ្ឋអាមេរិក | 2.8 | 2 | 1.1 | -0.9 |
| តំបន់អឺរ៉ុប | 2.8 | 2.6 | 0.7 | -1.9 |

*កំណត់សំគាល់: នេះ គឺជាទិន្នន័យដើមសំរាប់តារាង១ នៃអត្ថបទទី ៣ នៃសង្ខេបអត្ថបទរបស់លោក J. Menon ។ សូមកត់សំគាល់ផងដែរថា ក្រាហ្វិកទាំងអស់ក្នុងអត្ថបទនេះ យកចេញដោយផ្ទាល់ពីបទបង្ហាញនានា ។*

**ក្រាហ្វិក ១: កំណើនផលិតផលឧស្សាហកម្ម[1] (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)**




*១ មធ្យមភាគរំកិលបីខែ*

*២ សំដៅលើអាស៊ាន-៤ គឺ ប្រទេសកូរ៉េ សិង្ហបុរី និង ថៃ ប៉ុន្តែមិនរាប់បញ្ចូល ហុងកុង ចិន ប្រ៊ុយនេ កម្ពុជា ឡាវ ភូមា និងវៀតណាម ដោយសារទិន្នន័យប្រចាំខែ មិនអាចរកបាន ។*

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

* លោក Jayant Menon ជាសេដ្ឋវិទូជាន់ខ្ពស់ នៃការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៃធនាគារអភិវឌ្ឍន៍អាស៊ី ។

ក្រាហ្វិក ២: ការនាំចូលទំនិញ[១] (គិតជា ដុល្លារUS, ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

២ សំដៅលើប្រទេសចិន ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤

ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC

ក្រាហ្វិក ៣: កំណើនការនាំចេញ[១] (គិតជា ដុល្លារUS, ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

២ រាប់បញ្ចូលទាំង ប្រទេសចិន ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤

ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC

ក្រាហ្វិក ៤: កំណើនផលិតកម្មឧស្សាហកម្ម[១] – អាស៊ាន-៤ និង វៀតណាម (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC

ការនាំចូលរបស់មហាអំណាចសេដ្ឋកិច្ចទាំង ៣ (G3) បានធ្លាក់ចុះយ៉ាងលឿន ។ ស្ថិតិបានពីតំបន់អាស៊ីបូព៌ា ដែលមានសេដ្ឋកិច្ចកំពុងឈានឡើង បានបង្ហាញថា ការធ្លាក់ចុះតំរូវការពីបណ្តាប្រទេសអភិវឌ្ឍន៍ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ការនាំចេញនៃប្រទេសមានសេដ្ឋកិច្ចកំពុងឈានឡើង ។ ក្រៅពីចិន កំណើនផលិតកម្មឧស្សាហកម្មនៅអាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង បានដាំក្បាលចុះពី ១១,១% នៅខែមករាកាលពីឆ្នាំមុន មកដល់ -៨% នៅខែមករា ២០០៩ (មធ្យមភាគបីខែរំកិល) (ក្រាហ្វិក ១) ។ បណ្តាប្រទេសក្នុងតំបន់ ដូចជា ចិន ប្រទេសឧស្សាហកម្មថ្មី (ក្រៅពី តៃវ៉ាន់) និង អាស៊ាន-៤ ក៏មានកំណើននៃតម្លៃនាំចេញ និងនាំចូល ផលិតផលធ្លាក់ដល់អវិជ្ជមានដែរ នៅចុងឆ្នាំ២០០៨ (ក្រាហ្វិក ២ និង ក្រាហ្វិក ៣) ។

បើពិនិត្យលំអិតលើស្ថានភាពខាងលើ ផលិតផលឧស្សាហកម្ម និងការនាំចេញរបស់ប្រទេសនីមួយៗក្នុងអាស៊ាន-៥ (រួមទាំង វៀតណាម) សុទ្ធតែធ្លាក់ចុះ ដោយសារតំរូវការពិភពលោកនូវផលិតផលរបស់ប្រទេសទាំងនេះ បានថយចុះ ។ រហូតមកដល់ត្រីមាសទី៣ ឆ្នាំ២០០៨ ផលិតកម្មឧស្សាហកម្មរបស់វៀតណាមរក្សាលំនឹងបានល្អគួរសម ប៉ុន្តែក្រោយមកក៏ទទួលរងផលប៉ះពាល់ពីវិបត្តិដែរ ដោយបានរួមចុះ ១៤% នៅខែមករា ២០០៩ (មធ្យមភាគបីខែរំកិលគិតពីមួយឆ្នាំទៅមួយឆ្នាំ) ។ប្រទេសអាស៊ាន-៥ ផ្សេងទៀត ជួបការរួមចុះផលិតកម្មឧស្សាហកម្មដូចគ្នា ប៉ុន្តែថៃមានសភាពធ្ងន់ធ្ងរជាងគេ (ក្រាហ្វិក ៤) ។ ការរីករាលខាងនយោបាយនៅក្នុងប្រទេសថៃ បាននាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះ ។ តំលៃនៃការនាំចេញ និងនាំចូលផលិតផលបានរួមចុះយ៉ាងខ្លាំងនៅចុងឆ្នាំមុន ។ នៅតំបន់អាស៊ាន-៤ តម្លៃនេះ ធ្លាក់ចុះអស់ ៦% និង ១១% ត្រឹមខែធ្នូ ២០០៨ (ក្រាហ្វិក ៦ និង ៧) ។ ក្នុងចំណោមប្រទេសអាស៊ាន-៤ ការនាំចេញរបស់ហ្វីលីពីនទទួលរងគ្រោះខ្លាំងជាងគេនៅក្នុងឆ្នាំ២០០៨ ។

ដោយសារឧស្សាហូបនីយកម្មនៅបណ្តាប្រទេសឧស្សាហកម្មថ្មី (NIEs) គឺជំរុញឡើងដោយការបើកចំហសេដ្ឋកិច្ច ដូច្នេះវិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរណាស់ដល់ប្រទេសទាំងនេះដែលត្រូវពឹងផ្អែកលើពាណិជ្ជកម្ម។ កំណើនផលិតកម្មឧស្សាហកម្មរបស់កូរ៉េ ធ្លាក់ចុះយ៉ាងខ្លាំងពីខែតុលា ២០០៨ ដល់ មករា ២០០៩ ។ នៅសិង្ហបុរី កំណើនផលិតកម្មឧស្សាហកម្ម បានធ្លាក់ចុះយ៉ាងគំហុកពីខែតុលា ២០០៧ ដល់ កក្កដា ២០០៨ ដោយធ្លាក់ចុះដល់កំរិតទាបបំផុតគឺ -១៧% នៅខែមករា ២០០៩ (ក្រាហ្វិក៥) ។ស្រដៀងគ្នានឹងនិន្នាការនៅអាស៊ាន-៤ដែរ កំណើនតម្លៃនាំចេញ និងនាំចូលផលិតផល នៅប្រទេសឧស្សាហកម្មថ្មី បានប្រែជាអវិជ្ជមាននៅចុងឆ្នាំ២០០៨ (ក្រាហ្វិក ៦ និង ក្រាហ្វិក ៧) ។ នៅខែធ្នូ ២០០៨

ក្រាហ្វិក ៥: កំណើនផលិតកម្មឧស្សាហកម្ម[១] - កូរ៉េ និង សឹង្ហបុរី
(ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ៦: កំណើនការនាំចេញទំនិញ[១] - ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤
(ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ៧: កំណើនការនាំចេញ[១] - ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤




១ មធ្យមភាគរំកិលបីខែ

២ *អាស៊ាន-៤ មាន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថៃ រីឯប្រទេសឧស្សាហកម្មថ្មី-៣ មាន ហុងកុង ចិន ។*

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

សកម្មភាពនាំចេញរបស់តៃវ៉ាន់ ធ្លាក់ចុះធ្ងន់ធ្ងរជាងប្រទេសឧស្សាហកម្មថ្មីៗផ្សេងទៀត ។

នៅខែមករា ២០០៩ ផលិតកម្មឧស្សាហកម្មនៅចិន នៅតែកើនឡើង ទោះបីយឺតជាមុនក្តី ដោយតួលេខមធ្យមភាគបីខែរំកិល មានកំរិត ៦,៤៣% ។ ការថយចុះការបញ្ជាទិញទំនិញនាំចេញ និងវិនិយោគ គឺជាមូលហេតុចំបងនៃការថយចុះកំណើន ទោះបីកត្តាផ្សេងទៀត ដូចជាការបិទរោងចក្រមួយចំនួនក្នុងពេលប្រកួតកីឡាអូឡាំពិកជាដើម ក៏មានចំណែកក្នុងការធ្លាក់ចុះនេះដែរ ។ ការនាំចេញរបស់ចិន កើនឡើងជាវិជ្ជមាននៅខែធ្នូ ២០០៩ ប៉ុន្តែប្រហែលយឺតជាងមុន (ក្រាហ្វិក ៣) ។ ក្នុងខែដដែលនោះ ការនាំចូលផលិតផលរួមចុះ ៩% (ក្រាហ្វិក ២) ។ នៅជប៉ុន ផលិតកម្ម និងពាណិជ្ជកម្មទទួលរងគ្រោះធ្ងន់ធ្ងរណាស់ ។ ផលិតកម្មឧស្សាហកម្មជប៉ុន ធ្លាក់ចុះគួរឱ្យបារម្ភអស់ប្រហែល ២៣% នៅខែមករា (មធ្យមភាគបីខែរំកិល ពីមួយឆ្នាំទៅមួយឆ្នាំ) (ក្រាហ្វិក ៨) ដោយសារតំរូវការសាកលនូវផលិតផលកម្មន្តសាលជប៉ុន បានធ្លាក់ចុះយ៉ាងខ្លាំង និងបញ្ហាចោទជាយូរមកហើយ នៃតំរូវការក្នុងស្រុកដែលស្ពឹកទ្រឹង ។ ការនាំចេញរបស់ជប៉ុន ធ្លាក់តម្លៃ ១០% នៅចុងឆ្នាំ២០០៨ (មធ្យមភាគបីខែរំកិល ពីមួយឆ្នាំទៅមួយឆ្នាំ) ។

## ផលប៉ះពាល់លើការប្រើប្រាស់ និងវិនិយោគ

ដោយមានចំណាយសាធារណៈជួយទ្រទ្រង់ផង ចំណាយប្រើប្រាស់នៅប្រទេសអាស៊ាន-៤ នៅតែមានកំណើនថេរជាវិជ្ជមាន ហើយវាបានផ្តល់ជំនួយទ្រទ្រង់ដ៏ចាំបាច់ដល់សេដ្ឋកិច្ចប្រទេសទាំងនេះ នៅចំពោះមុខការធ្លាក់ចុះវិនិយោគ ។ បន្ទាប់ពីមានកំណើនខ្ពស់ដល់ ៩,៣% នៅត្រីមាសទី១ ឆ្នាំ២០០៨ កំណើនវិនិយោគជាប់លាប់នៅក្នុងតំបន់ បានធ្លាក់ចុះមកត្រឹម ១,៦% វិញ នៅត្រីមាសទី៤ នៃឆ្នាំដដែល (ក្រាហ្វិក ៩) ។ ការថយចុះឥណទានយ៉ាងធ្ងន់ធ្ងរ ក្តីសង្ឃឹមតិចតួចចំពោះកំណើន និងកំណើនការប្រុងប្រយ័ត្នរបស់វិនិយោគិន ជាកត្តាចំបងនៃការធ្លាក់ចុះនេះ ។ វិនិយោគជាប់លាប់នៅក្នុងប្រទេសឧស្សាហកម្មថ្មី បានរួមចុះខ្លាំងជាងនៅអាស៊ាន-៤ ទៀត ដោយកំណើនតិចតួចត្រឹម ៣,៣% កាលពីត្រីមាសទី៣ ឆ្នាំ២០០៨ បានធ្លាក់ចុះភ្លាមៗអស់ ១០% នៅត្រីមាស ទី៤ ក្នុងឆ្នាំដដែល ។ ផ្ទុយស្រឡះពីអាស៊ាន-៤ នៅប្រទេសឧស្សាហកម្មថ្មី ចំណាយប្រើប្រាស់ធ្លាក់ចុះ ២% នៅត្រីមាស ទី៤ ឆ្នាំ២០០៨ (ក្រាហ្វិក ១០) ។ រដ្ឋាភិបាលនៃប្រទេសឧស្សាហកម្មថ្មី បានអនុម័តវិធានការផ្សេងៗ ដូចជា កញ្ចប់សារពើពន្ធជំរុញតំរូវការក្នុងស្រុក ជាដើម ប៉ុន្តែវិធានការទាំងនោះ មិនទាន់ហុចលទ្ធផលជាដុំកំភួនទេ ។

ក្រាហ្វិក ៨: កំណើនផលិតផលឧស្សាហកម្ម: ជប៉ុន[១] (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*១ មធ្យមភាគរំកិលបីខែ*

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ៩: កំណើនតំរូវការក្នុងស្រុក – អាស៊ាន-៤ (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ១០: កំណើនតំរូវការក្នុងស្រុក – ប្រទេសឧស្សាហកម្មថ្មី–៣ (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ភាគហ៊ុននៅអាស៊ាន-៤ និងប្រទេសឧស្សាហកម្មថ្មី ក៏ធ្លាក់ថ្លៃដែរ ហើយវាបានប៉ះពាល់ដល់វិនិយោគ និងចំណាយប្រើប្រាស់ឯកជន ។ នៅកូរ៉េខាងត្បូង និងតៃវ៉ាន់ សន្ទស្សន៍ទីផ្សារហ៊ុនធ្លាក់ចុះប្រហែល ៣៥% ទៅ ៤០% ដោយសារការរឹតបន្តឹងលក្ខខណ្ឌឥណទាន ការថយចុះតំរូវការនូវផលិតផលបច្ចេកវិទ្យានាំចេញ ហើយគំរោងវិនិយោគនៅក្រៅប្រទេស ក៏ទទួលការខាតបង់ច្រើនគួរកត់សំគាល់ ។ សន្ទស្សន៍ហ៊ុនរបស់ឥណ្ឌូនេស៊ី និងថៃធ្លាក់ចុះប្រហែល ៥០% ។ រូបិយវត្ថុភាគច្រើននៅតំបន់ទាំងនេះ ធ្លាក់ថ្លៃខ្លាំងបន្ទាប់ពីជួបវិបត្តិ ។ ក្នុងចំណោមប្រទេសឧស្សាហកម្មថ្មី រូបិយវត្ថុរបស់កូរ៉េខាងត្បូងធ្លាក់ថ្លៃខ្លាំងជាងគេ ដោយសារឱនភាពគណនីចរន្តរីកធំ និងការដកចេញយ៉ាងគំហុកនូវវិនិយោគបរទេសលើមូលប័ត្រ ។ ក្នុងចំណោមប្រទេសអាស៊ាន៤ ប្រាក់រូពីរបស់ឥណ្ឌូនេស៊ី រងគ្រោះខ្លាំងជាងគេ ដោយសារការថយចុះយ៉ាងខ្លាំងនូវវិនិយោគបរទេសលើភាគហ៊ុន និងការរត់ចេញទៅវិញនូវទុនវិនិយោគបរទេស ។

## ចក្ខុវិស័យ និងគោលនយោបាយឆ្លើយតប

សេដ្ឋកិច្ចក្នុងតំបន់ និងសាកលលោក នៅតែស្ថិតក្នុងបរិយាកាសអាប់អួរ ហើយការខូចខាតកាន់តែធ្ងន់ធ្ងរ នៅតែអាចកើតមាន ។ ស្ថានភាពបច្ចុប្បន្ន បង្ហាញពីហានិភ័យនៃការធ្លាក់ចុះកាន់តែខ្លាំង ។ ស្របតាមគំនិតនេះ ការគន់គូរពីកំណើន ក៏មានលក្ខណៈកាន់តែទុទិដ្ឋិនិយម ។ ផ្អែកលើតួលេខប៉ាន់ស្មានរបស់ IMF គេរំពឹងថា នៅឆ្នាំ២០០៩ សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ នឹងរួមចុះ ១,៦% និង ២% ចំណែកឯសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីនឹងមានកំណើនយឺតជាងមុន ។ រដ្ឋាភិបាលនៅគ្រប់ប្រទេស រួមទាំងតំបន់អាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើងនោះផង បានចាត់វិធានការយ៉ាងរហ័ស និងម៉ឹងម៉ាត់ដោះស្រាយបញ្ហាផុសចេញពីវិបត្តិ ។ ធនាគារកណ្តាលចំបងៗក្នុងពិភពលោក បានចាត់វិធានការពិសេស និងជាប្រវត្តិសាស្ត្រ ដូចជាការដាក់បញ្ចូលសាច់ប្រាក់យ៉ាងច្រើនទៅក្នុងគ្រឹះស្ថាន និងទីផ្សារ ជាដើម ដើម្បីជួយសំរាលនិងទប់ទល់ការប៉ះទង្គិច ។ ធនាគារកណ្តាលសហរដ្ឋអាមេរិកបានបញ្ចុះអត្រាការប្រាក់ ឱ្យនៅទាបបំផុត មិនធ្លាប់មាន ក្នុងប្រវត្តិសាស្ត្រនៃគោលនយោបាយរូបិយវត្ថុសម័យទំនើប ។ ប្រទេសនៅតំបន់អឺរ៉ុប បានចាត់វិធានការពិសេសបំផុត ដើម្បីជួយសង្គ្រោះប្រព័ន្ធធនាគារ ដោយក្នុងនោះ ប្រទេសដាណឺម៉ាក និងអៀរឡង់ បានប្រកាសផ្តល់ការធានាជាទូទៅដល់ប្រាក់បញ្ញើ និងបំណុល ។ នៅអាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង មានការអនុម័តកញ្ចប់ជំរុញខាងហិរញ្ញវត្ថុផ្សេងៗ ដើម្បីបង្កើនចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសុវត្ថិភាពសង្គម ។ ការកាត់បន្ថយពន្ធ និងបង្កើនឧបត្ថម្ភធន ក៏បានផ្តួចផ្តើមធ្វើឡើង ដើម្បីជួយដល់សេដ្ឋកិច្ចដែលកំពុងធ្លាក់ចុះ ។ ទោះបីជាមានវិធានការដ៏ម៉ឹងម៉ាត់បែបនេះក្តី ក៏ស្ថានភាពហិរញ្ញវត្ថុនៅតែតឹងតែង ហើយតំរូវការក្នុងស្រុកនិងក្រៅស្រុកនៅតែមានតិច ដូច្នេះហើយ គេក៏ព្យាករណ៍ថា ការរើបសេដ្ឋកិច្ចឡើងវិញ នឹងមានល្បឿនយឺត ៕